# សេចក្តីថ្លែងការណ៍

# ឆ្លើយតបនៅនឹងការចោទប្រកាន់របស់ក្រុមហ៊ុនភ្នំពេញស៊ូហ្គើរ

# លើលោក អៀង វុទ្ធី នាយកប្រតិបត្តិ អង្គការសមធម៌កម្ពុជា

កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ក្រុមហ៊ុនភ្នំពេញស៊ូហ្គើរ បានចេញផ្សាយអត្ថបទក្នុងសារ ព័ត៌មានក្នុងស្រុកមួយចំនួន ដោយបានចោទប្រកាន់នាយកប្រតិបត្តិ អង្គការសមធម៌កម្ពុជា លោក អៀង វុទ្ធី ពីបទធ្វើសេចក្តីថ្លែងការក្លែងក្លាយ និងបន្លំ ទាក់ទងទៅនឹងលោកឧកញ៉ា លី យ៉ុងផាត់ ដែលបណ្តាល អោយមាន "ការខូចខាតដែលមិនអាចស្រោចស្រង់វិញបាន" លើកេរ្តិ៍ឈ្មោះ របស់ លោកឧកញ៉ា ក៏ដូចជា អាជីវកម្មរបស់ក្រុមហ៊ុនស៊ូហ្គើរភ្នំពេញ។

ប៉ុន្តែ ក្នុងពេលធ្វើសន្និសិទការសែត លោកអៀង វុទ្ធី មិនបាននិយាយអ្វីដែលបង្ហាញថា សមាជិកព្រឹទ្ធ សភារូបនេះមានជាប់ពាក់ព័ន្ធក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុនទាំងពីរនេះក្នុងពេលបច្ចុប្បន្ននោះទេ។ វីដេអូដែលថតបានក្នុងអំឡុងពេលធ្វើសន្និសិទការសែតអាចបញ្ជាក់ពីការអំណះអំណាងនេះបាន ។

អ្វីដែលសំខាន់គឺ ក្នុងសន្និសិទការសែតមួយកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤ លោក អៀង វុទ្ធី បានបង្ហាញពីការជាប់ពាក់ព័ន្ធរបស់ លោក លី យ៉ុងផាត់ លើដីសម្បទានសេដ្ឋកិច្ចសម្រាប់ដាំអំពៅដើម្បីផលិត ស្ករសក្នុងខេត្តកោះកុង និងខេត្តឧត្តរមានជ័យ។ នៅក្នុងអត្ថបទចុះផ្សាយក្នុងសារព័ត៌មាន ក្រុមហ៊ុន ភ្នំពេញស៊ូហ្គើរ បានអះអាងថា "ការចោទប្រកាន់" បែបនេះ គឺមានលក្ខណៈ "មិនមានការទទួលខុសត្រូវ និងគ្មានមូលដ្ឋានច្បាស់លាស់ទាល់តែសោះ។"

ទោះបីជាពេលថ្មីៗនេះសមាជិកព្រឹទ្ធសភារូបនេះ ប្រហែលជាមិនជាប់ពាក់ព័ន្ធក្នុងការគ្រប់គ្រង ឬ កាន់កាប់ក្រុមហ៊ុន កនកែនស៊ូហ្គើរ ក្នុងខេត្តកោះកុង ឬ ក្រុមហ៊ុន មិត្រ ប៉ូល ស៊ូហ្គើរ ក្នុងខេត្តឧត្តរមានជ័យ ក៏ដោយ ក៏មានភស្តុតាងដែលមិនអាចប្រកែកបាន ថា លោកឧកញ៉ា លី យ៉ុងផាត់ មានជាប់ពាក់ព័ន្ធជាមួយ ក្រុមហ៊ុនទាំងពីរនេះ រួមជាមួយនិងការណ្តេញប្រជាពលរដ្ឋរាប់ពាន់នាក់ចេញ ដោយបង្ខំ។

## ការជាប់ពាក់ព័ន្ធរបស់លោកឧកញ៉ា លី យ៉ុងផាត់ ក្នុងការទទួលបានដីសម្បទានសម្រាប់ដាំដំណាំអំពៅ ផលិតស្ករសរក្នុងខេត្តកោះកុង

លោកឧកញ៉ា លី យ៉ុងផាត់ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីជាអតីតប្រធាន និងជាភ្នាក់ងារចុះបញ្ជី អោយក្រុមហ៊ុនដាំដុះក្នុងខេត្តកោះកុង លើគេហទំព័រផ្លូវការរបស់ ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រ កម្ពុជា។ អាសយដ្ឋាននៃការិយាល័យកណ្តាលរបស់ក្រុមហ៊ុននេះ (ដូចដែលបានបង្ហាញក្នុងសេចក្តីប្រកាស នៃការបង្កើតសហគ្រាសពាណិជកម្មសម្រាប់ក្រុមហ៊ុនដាំដុះខេត្តកោះកុង) គឺស្ថិតនៅជាមួយក្រុមហ៊ុន វាយ អិល ភី គ្រុប ដែលមានទីតាំងផ្ទះលេខ ២០៥-២០៧ មហាវិថីម៉ៅសេទុង។[i]

លោកឧកញ៉ា លី យ៉ុងផាត់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ដីសម្បទានសម្រាប់ក្រុមហ៊ុន ដាំដុះខេត្តកោះកុង កាលពីថ្ងៃទី២ ខែសីហា ឆ្នាំ២០០៦ ហើយពេលនោះគាត់មានឈ្មោះជានាយកក្រុមហ៊ុនផង ដែរ។[ii]

នៅថ្ងៃដែលក្រុមហ៊ុនដាំដុះខេត្តកោះកុងទទួលបានដីសម្បទាននោះ មានដីមួយកន្លែងទៀត ដែល មានទីតាំងក្បែរគ្នានោះត្រូវបានសម្បទានទៅអោយក្រុមហ៊ុន កោះកុង ស៊ូហ្គើរ ផងដែរ។ ដីសម្បទានទាំង ពីរនេះរួមបញ្ចូលគ្នាបង្កើតបានជាតំបន់ឧស្សាហកម្មដាំអំពៅ ដែលមានទំហំសរុប ២០,០០០ ហិចតា។ ក្រុមហ៊ុនទាំងពីរនេះត្រូវបានបង្កើតឡើងដោយការរួមបញ្ចូលរវាងក្រុមហ៊ុន ខេអេសអិល គ្រុប របស់ ប្រទេសថៃ ក្រុមហ៊ុន វ៉េ ហ្វាំង សាជីវកម្មរបស់តៃវ៉ាន់ និងក្រុមហ៊ុនលីយ៉ុងផាត់[iii] ។ បច្ចុប្បន្ន ក្រុមហ៊ុន ខេអេសអិល គ្រុប បានកាន់កាប់ភាគហ៊ុនចំនួន៧០% នៃក្រុមហ៊ុនទាំងពីរ[iv] ចំណែកក្រុមហ៊ុន វ៉េ ហ្វាំង សហប្រតិបត្តការ កាន់កាប់ភាគហ៊ុនចំនួន ៣០% ។[v] យោងតាមគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម បានឲ្យដឹងថា ក្រុមហ៊ុនលី យ៉ុងផាត់ បានលក់ភាគហ៊ុន ២០% របស់ខ្លួន ទៅអោយក្រុមហ៊ុន ខេអេសអិល គ្រុប ក្នុងឆ្នាំ២០១០។[vi]

សេចក្តីអំពាវនាវអោយមានចំណាត់ការបន្ទាន់របស់គណៈកម្មការសិទ្ធិមនុស្សអាស៊ី បានបង្ហាញ យ៉ាងលំអិតអំពីការបណ្តេញប្រជាពលរដ្ឋចំនួន ២៥០ គ្រួសារចេញពីឃុំជីខរលើ ដើម្បីអោយក្រុមហ៊ុន ធ្វើការដាំដុះ កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៦៖

> នគរបាលបានបំផ្លាញដំណាំ និងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ដោយប្រើប្រាស់គ្រឿងចក្រធំៗ ហើយ បានវាយប្រហារយ៉ាងសាហាវយង់ឃ្នងលើក្រុមប្រជាពលរដ្ឋដែលប្រឆាំងតវានឹងការការបណ្តេញ ចេញនេះ។ មានសេចក្តីរាយការណ៍ថា ប្រជាពលរដ្ឋចំនួន៥ នាក់បានទទួលរងរបួសយ៉ាងធ្ងន់ធ្ងរ បន្ទាប់ពីការវាយដំពីនគរបាល ហើយពីរនាក់ផ្សេងទៀតទទួលរងរបួសពីការបាញ់កាំភ្លើងរបស់មន្ត្រី ប៉េអឹម។[vii] បើ

យោងទៅតាមរបាយការណ៍ ប្រជាពលរដ្ឋ២នាក់រងរបួស ដោយសារគ្រាប់កាំភ្លើង ចំណែកសមាជិកសហគមន៍ផ្សេងទៀត ត្រូវបានវាយដំដោយស្នូកកាំភ្លើង។[viii]

របាយការណ៍ឆ្នាំ២០០៧ របស់តំណាងពិសេសអង្គការសហប្រជាជាតិ របស់អគ្គលេខាដើម្បីសិទ្ធិ មនុស្សក្នុងប្រទេសកម្ពុជា បានចងក្រង និងកត់ត្រាពីផលប៉ះពាល់លើកដំបូងនៃការផ្ដល់ដីសម្បទាននេះ៖

ការឈូសឆាយវាលស្រែ និងដីចំការដែលជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងស្រុកស្រែអំបិលបានប៉ះពាល់ដល់ប្រជាពលរដ្ឋជាង ៤០០ គ្រួសារ។ អ្នកខ្លះសល់ដីបន្តិចបន្តួច ឬគ្មានដីសេស សល់ បន្តិចសោះ ហើយពឹងផ្អែកលើផលដែលប្រមូលបានកាលពីឆ្នាំមុន។ ការផ្ដល់ដីសម្បទាន ក៏បង្ក អោយមានការហាមឃាត់មិនអោយសត្វចញ្ចឹមរបស់ប្រជាពលរដ្ឋចូលស៊ីស្មៅ នៅក្នុងដីនោះដែរ ហើយមានសេចក្តីរាយការណ៍ថា សន្តិសុខរបស់ក្រុមហ៊ុន បានចាប់ ឬបាញ់សម្លាប់សត្វចិញ្ចឹមរបស់ ប្រជាពលរដ្ឋណាដែលចូលក្នុងតំបន់សម្បទាននេះ។[ix]

ការរំលោភបំពានសិទ្ធិមនុស្សទាំងនេះបានកើតមានឡើងក្នុងឆ្នាំ ២០០៦ និងឆ្នាំ ២០០៧ នៅ ក្នុងអំឡុងពេលដែលលោកឧកញ៉ា លី យ៉ុងផាត់ ជាប្រធានក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនទាំងនេះ និងក្រុមហ៊ុនសហកម្មសិទ្ធិជាច្រើនទៀត។ បន្ទាប់ពីការទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងការឈឺចាប់ អស់រយៈពេលជាច្រើនឆ្នាំ ដែលបង្កឡើងដោយក្រុមហ៊ុនដាំណាំអំពៅទាំងនោះ គ្រួសារដែលទទួលរងផល ប៉ះពាល់នៅតែតស៊ូទាមទារសំណាងសមស្របណាមួយសម្រាប់ពួកគាត់។

## ការជាប់ពាក់ព័ន្ធរបស់លោកឧកញ៉ា លី យ៉ុងផាត់ ក្នុងការទទួលបានដីសម្បទានសម្រាប់ដាំដំណាំអំពៅ ផលិតស្ករសក្នុងខេត្តឧត្តរមានជ័យ

កាលពីឆ្នាំ២០០៧ ដីសម្បទានសេដ្ឋកិច្ចចំនួនបីកន្លែងក្នុងខេត្តឧត្តរមានជ័យត្រូវបានផ្ដល់ទៅអោយ ក្រុមហ៊ុន អង្គរ ស៊ូហ្គើរ, ក្រុមហ៊ុនទន្លេ ស៊ូហ្គើរខេន, និងក្រុមហ៊ុន ខេន អេន ស៊ូហ្គើ វាឡេ។ ក្រុម ហ៊ុនទាំងនេះត្រូវបានគេជឿជាក់ថាជាកម្មសិទ្ធិទាំងមូល ឬផ្នែកខ្លះរបស់ក្រុមហ៊ុនស្ករធំបំផុតរបស់ប្រទេស ថៃ ដែលមានឈ្មោះថា មិត្រ ផុល។ ប៉ុន្តែ វាត្រូវបានគេមើលឃើញយ៉ាងច្បាស់ថា លោកឧកញ៉ា លី យ៉ុងផាត់ ពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មទាំងនេះ។ ដោយយោងទៅនឹងគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម ក្នុង អំឡុងពេលបង្កើតក្រុមហ៊ុនទាំងបីនេះ ការិយាល័យកណ្តាលរបស់ក្រុមហ៊ុនទាំងនេះ មានអាសយដ្ឋាននៅជាមួយនឹងក្រុមហ៊ុន អិលវាយភីគ្រុប។[x]

នៅក្នុងឆ្នាំ២០០៧ អាជ្ញាធរមូលដ្ឋានបានប្រាប់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីការផ្តល់ដី សម្បទាននេះថា ប្រសិនបើពួកគេចង់ប្តឹងក្រុមហ៊ុនទាំងបីនេះ ពួកគេគួរតែប្តឹទៅលោកឧកញ៉ា លី យ៉ុងផាត់ "ព្រោះគាត់ជាអ្នកទទួលខុសត្រូវលើក្រុមហ៊ុនទាំងនេះ" ។[xi]

ក្នុងខែមេសា ឆ្នាំ២០០៨ បុគ្គលិករបស់ក្រុមហ៊ុនអង្គរ ស៊ូហ្គើរ ពាក់អាវយឺតដោយមានសរសេរពាក្យថា "*ជាអំណោយរបស់ឧកញ៉ា លី យ៉ុងផាត់*" បានរុះរើរបំផ្លាញលំនៅដ្ឋានប្រជាពលរដ្ឋចំនួន ១៥៤ ខ្នង ស្ថិតក្នុងភូមិបោះ/អូរបាត់មាន់ ក្រោមការចង្អុលបង្ហាញរបស់អាជ្ញាធរមូលដ្ឋាន។

ការបណ្តេញចេញបន្ថែមទៀតត្រូវបានអនុវត្តក្នុងខែតុលា ឆ្នាំ២០០៩ នៅពេលដែលលំនៅដ្ឋាន ជាកម្មសិទ្ធិរបស់១០០គ្រួសារ ដែលរស់នៅក្នុងភូមិបោះ/អូរបាត់មាន់ ត្រូវបានដុតបំផ្លាញ និងឈូស ឆាយដោយកងកំលាំងប្រហែលជាង១៥០នាក់ដែលក្នុងនោះរួមមាននគរបាល ប៉េអឹម កម្មករស៊ីឈ្នួល និងទាហ៊ានកងយុទ្ធពលខេមរភូមិន្ទមកពីកងពលតូចលេខ ៤២។ កងពលតូចលេខ៤២នេះគឺជាកង ទាហ៊ាន ដែលទទួលបានការឧបត្ថមជាផ្លូវការពីកាស៊ីណូអូស្មាច់របស់លោក លី យ៉ុងផាត់ ក្នុងខេត្តឧត្តរមាន ជ័យ។[xii] ក្រុមកងកំលាំងនេះបិទផ្លូវ និងបន្តការដុតបំផ្លាញ និងឈូសឆាយបផ្ទះរបស់ប្រជាពលរដ្ឋ។[xiii]

ប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយការបណ្តេញចេញដោយបង្ខំ គឺរស់នៅដោយគ្មានផ្ទះសម្បែង គ្មានដីធ្លី ហើយស្ថិតក្នុងស្ថានភាពដែលត្រូវការជំនួយមនុស្សធម៌ជាចាំបាច់។ តាំងពីត្រូវបានបណ្តេញចេញពីដីរបស់ ខ្លួនមក ពួកគាត់ភាគច្រើនគ្មានម្ហូបអាហារ មិនអាចទទួលបានការថែទាំសុខភាពជាមូលដ្ឋាន ឬជម្រក ជាអចិន្ត្រៃយ៍ណាមួយឡើយ។ [xiv] មកដល់ពេលនេះ គ្រួសារដែលទទួលរងផលប៉ះពាល់ មិនទាន់ធ្លាប់បាន ទទួលសំណងណាមួយឡើយ។

---

**លោក លី យ៉ុងផាត់ គួរតែបន្ទោសខ្លួនឯងសម្រាប់ការធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ និងអាជីវកម្មក្រុមហ៊ុន ភ្នំពេញ ស៊ូហ្គើររបស់ខ្លួន។ ប្រសិនបើគាត់ចង់កែលំអកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើងវិញ គាត់គួរតែផ្តល់សំណង ប្រកបដោយភាព ត្រឹមត្រូវ តម្លាភាព និងយុត្តធម៌ជូនដល់គ្រួសារដែលទទួលរងផលប៉ះពាល់ ក្នុងខេត្តកោះកុង ខេត្តកំពង់ស្ពឺ និងខេត្តឧត្តរមានជ័យ ដែលជីវភាពរបស់ពួកគាត់ត្រូវបានបំផ្លាញដោយសារសកម្មភាពអាជីវកម្មដែលគ្មានការ កោតក្រែងរបស់គាត់។ យើងនៅតែបើកចំហរសម្រាប់ការប្រជុំជាមួយនឹងសមាជិកព្រឹទ្ធិសភារូបនេះ នៅពេលណាដែលគាត់ត្រៀមខ្លួនរួចជាស្រេច ក្នុងការចូលរួមប្រជុំដើម្បីពីភាក្សាប្រកបដោយអត្ថន័យអំពីដំណោះស្រាយនានាជូនដល់គ្រួសាររងគ្រោះ។**

---

សេចក្តីថ្លែងការណ៍នេះត្រូវបានចេញផ្សាយដោយអង្គការសមធម៌កម្ពុជា, អង្គការអភិវឌ្ឍន៍សម្លេង សហគមន៍ (BCV), ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF), បណ្តាញកសាងសន្តិភាព (CPN) សម្ព័ន្ធខ្មែរជំរឿន និងការសិទ្ធិមនុស្ស លីកាដូ, មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC), និង អង្គការ អភិវឌ្ឍន៍ដោយមានការចូលរួមអន្តរជាតិ (IDI)។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទៅកាន់:**


លោក អៀង វុទ្ធី នាយកប្រតិបត្ត
អង្គការសមធម៌កម្ពុជា (EC)
ទូរស័ព្ទ: (+855) 12 791 700
អ៊ីម៉ែល: vuthy@equitablecambodia.org

លោក យ៉េង វីរៈ នាយកប្រតិបត្ត
មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
ទូរស័ព្ទ: (+855) 12 801 235
អ៊ីម៉ែល: virakyeng@clec.org.kh

កញ្ញា ណាលី ពីឡូក នាយក
សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
ទូរស័ព្ទ: (+855) 12 803 650
អ៊ីម៉ែល: director@licadho-cambodia.org

អ្នកស្រី ត្រី ផល្លី ផួង នាយកប្រតិបត្ត
អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV)
ទូរស័ព្ទ: (+855) 89 885 625
អ៊ីម៉ែល: phuongbcv@gmail.com

លោក សេង សុខហេង អ្នកសម្របសម្រួលលេខាធិការ
បណ្តាញកសាងសន្តិភាព (CPN)

ទូរស័ព្ទ: (+855) 92 324 668
អ៊ីម៉ែល: seng.sokheng@gmail.com

លោក ស៊ា ភារម្យ នាយក
ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF)
ទូរស័ព្ទ: (+855) 60 313 451
អ៊ីម៉ែល: sd@hrtfcambodia.org

លោក ដេវិត   ប្រេដ នាយក
អង្គការអភិវឌ្ឍន៍ដោយមានការចូលរួមអន្តរជាតិ (IDI)
ទូរស័ព្ទ: +1 (917) 280-2705
អ៊ីម៉ែល: david@inclusivedevelopment.net

## ប្រភព:

---

[i] *See*: http://www.moc.gov.kh/Company/Detail.aspx?MenuID=18&NoticeID=1&ID=20191

[ii] *See*: http://www.opendevelopmentcambodia.net/pdf-viewer/?pdf=references/Koh_Kong_Plantation_Company_Ltd__02.08.2006.pdf

[iii] Aranee Jasmin, "ក្រុមហ៊ុន ខេអេសអិលចូលរួមជាក្រុមហ៊ុនសហកម្មសិទ្ធជាមួយក្រុមហ៊ុនប្រទេសកម្ពុជា" បាងកក ប៉ុស្ត៍, ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៦

[iv] របាយការណ៍ប្រចាំឆ្នាំ២០១១របស់ក្រុមហ៊ុន ខេអេសអិល ទំព័រទី ៦។ *អាចរកបានតាមរយៈ*: http://www.kslsugar.com/contents/files/annualreport/annualreport-en-30042012-130902-686498.pdf.

[v] "ក្រុមហ៊ុន វ៉េ ហ្វុង ឆ្លើយតបទៅនឹងការចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស និងការរឹបអូសដីដោយក្រុមហ៊ុនផលិតស្ករស ក្នុងប្រទេសកម្ពុជា, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២។ *អាចរកបានតាមរយៈ*: http://www.business-humanrights.org/media/ve-wong-response-re-cambodian-sugar-18-jul-2012-en.doc.

[vi] *Ibid*.

[vii] គណកម្មាធិការសិទ្ធិមនុស្សអាស៊ាន (AHRC), "កម្ពុជា: ប្រជាពលរដ្ឋពីរនាក់ត្រូវបានបាញ់សម្លាប់ និងមនុស្សមួយចំនួនទទួលរងរបួសក្នុងពេលការបណ្តេញដោយបង្ខំក្នុងខេត្តកោះកុង, ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៦។ *អាចរកបានតាមរយៈ* http://www.humanrights.asia/news/urgent-appeals/UA-321-2006.

[viii] *Ibid*.

[ix] តំណាងពិសេសអង្គការសហប្រជាជាតិ របស់អគ្គលេខាដើម្បីសិទ្ធិ មនុស្សក្នុងប្រទេសកម្ពុជា (UNSRSG), "ដីសម្បទានសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា: ទស្សនៈទានសិទ្ធិមនុស្ស," ចុះខែមិថុនា ឆ្នាំ២០០៧ ទំព័រទី១២។ *អាចរកបានតាមរយៈ* http://cambodia.ohchr.org/WebDOCs/DocReports/2-Thematic-Reports/Thematic_CMB12062007E.pdf.

[x] http://www.moc.gov.kh/Company/Detail.aspx?MenuID=18&NoticeID=1&ID=12805

[xi] របាយការណ៍ដោយអង្គការលីកាដូរ "របាយការណ៍សង្ខេប: ភូមិបោះ/អូបាត់មាន់ ឃុំកូលគ្រោល ស្រុកសំរោង ខេតឧត្តរមានជ័យ," ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩។ ហើយត្រូវបានបញ្ជាក់ឡើងវិញដោយអង្គការសមធម៌កម្ពុជា ក្នុងពេលសម្ភាសន៍ជាមួយប្រជាពលរដ្ឋក្នុងស្រុកសំរោង ក្នុងខែកុម្ភៈ ឆ្នាំ២០១៣។

[xii] ភ្នំពេញប៉ុស្ត៍, ជេមស៍ អូទូល & លឹម ផល្លា: "ឯកសារបង្ហាញពីចំណងទាក់ទងរវាងកងយុទ្ធពលខេមរភូមិន្ទ និងវិស័យឯក

ជន,” ថ្ងៃទី៤ ខែមិនា ឆ្នាំ២០១០។ *អាចរកបានតាមរយៈ:* http://www.phnompenhpost.com/national/document-shows-ties-among-rcaf-government-and-private-sector. *សូមអានផងដែរ*: ខេមបូឌា ដេលី, ផន បុប្ផា & ជូលី វាលេក្ស: “ចំណាងអាជីវកម្មជាមួយមន្ត្រី មិនមែនជាមួយយោធា,” ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០

[xiii] របាយការណ៍សង្ខេបរបស់អង្គការលីកាដូ, *supra* note x.

[xiv] *Ibid*.